# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រៃវែង**
លេខ ៖ ......០២០/២១.........ក.ប/ព.វ

## ជម្រាបមក
**លោក/លោកស្រី នាយកក្រុមហ៊ុន អរិន មេនូហ្វេកធីរីង (ខ្មែរ) (វិស័យ កាត់ដេរ)**
អាសយដ្ឋាន ឃុំ/សង្កាត់ ស្មោងខាងជើង ក្រុង/ស្រុក/ខណ្ឌ កំចាយមារ រាជធានី/ខេត្ត ព្រៃវែង

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករ និយោជិត
**យោង** ៖ លិខិតលេខ ២១០២១៧៧៤២២ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រុមហ៊ុន អរិន មេនូហ្វេកធីរីង (ខ្មែរ)

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក/លោកស្រី នាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករ និយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករ និយោជិតចំនួន ១០២៣នាក់ (ស្រី ៩០៤នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ១៦០៥នាក់ (ស្រី១៤០១នាក់) រយៈពេលចំនួន ៣១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែមីនា រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ក្នុងនោះ ៖

-កម្មករ និយោជិតចំនួន ១០២០នាក់ (ស្រី ៩០២នាក់) ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗ ចំនួន ៤០ដុល្លារអាមេរិកក្នុងមួយខែ

-កម្មករ និយោជិតចំនួន ៣នាក់ (ស្រី ២នាក់) មិនទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល ។

ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់ កម្មករ និយោជិត ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោក/លោកស្រី នាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់ និងចំនួនដែលបានព្រមព្រៀងគ្នា ។

ក្នុងករណី **លោក/លោកស្រី នាយក** ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការ ហើយ **លោក/លោកស្រី** ត្រូវទទួលខុសត្រូវបង់ជួសកម្មករ និយោជិតទៅតាមចំនួនប្រាក់ឧបត្ថម្ភបានផ្ទេរកម្មករ និយោជិត ដែលបានចូលធ្វើការមុនកំណត់ទាំងនេះ ។ ក្នុងករណីចាំបាច់ **លោក/លោកស្រី** អាចស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់បានចំនួន ១លើក ។ ករណីលើសពី ១លើក **លោក/លោកស្រី** ត្រូវទទួលខុសត្រូវចេញប្រាក់ឧបត្ថម្ភជំនួសរាជរដ្ឋាភិបាលឱ្យទៅកម្មករ និយោជិតដែលនៅសល់រហូតដល់បញ្ចប់ការព្យួរកិច្ចសន្យាការងារ ។

អាស្រ័យដូចនេះ សូម **លោក/លោកស្រី នាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករ និយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោក/លោកស្រី នាយក** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ៕

ថ្ងៃចតុទ្ទសី ១៤ កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ព្រៃវែង ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១
**ត.ប. រដ្ឋមន្ត្រី**
**ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ណារុប_សារ៉ាត

**ចម្លងជូន:**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលខេត្ត